**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ឆ្វៀលដីទំហំ ៧៦ ហិកតា ០៩ អា និង ៤២ សង់ទីអា ស្ថិតនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចេញពីដែនគម្រប់ព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងផ្តល់កម្មសិទ្ធិជូនប្រជាពលរដ្ឋដែលកាន់កាប់ជាក់ស្តែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ត្រូវបានកាត់ឆ្វៀលដីទំហំ ៧៦ ហិកតា ០៩ អា និង ៤២ សង់ទីអា ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ។

**មាត្រា២ .-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីទំហំ ៧៦ ហិកតា ០៩ អា និង ៤២ សង់ទីអា ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជូនឈ្មោះ កើត សុទ្ធារ៉ា ដែលកាន់កាប់ជាក់ស្តែង។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីបង្ហាញក្បាលដីទំហំ ៧៦០ ៩៤២ ម៉ែត្រក្រឡា ស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ជូនឈ្មោះ គើត សុទ្ធារ៉ា
ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
(ដែនគម្របព្រៃឈើឆ្នាំ ២០០២)




តារាងនិយាមកាព្រំដីស្នើសុំកាត់ចេញ
ពីដែនគម្របព្រៃឈើឆ្នាំ២០០២
Projection, UTM Zone 48N, Datum, WGS, 1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 346199.549 | 1169880.945 | 23 | 347277.937 | 1169928.857 |
| 2 | 346212.918 | 1169874.462 | 24 | 347338.092 | 1169992.924 |
| 3 | 346302.320 | 1169819.977 | 25 | 347363.307 | 1170012.155 |
| 4 | 346384.254 | 1169772.483 | 26 | 347450.222 | 1170063.169 |
| 5 | 346590.646 | 1169648.309 | 27 | 347532.296 | 1170046.203 |
| 6 | 346581.050 | 1170155.253 | 28 | 347585.673 | 1170124.792 |
| 7 | 346567.129 | 1170156.709 | 29 | 347640.201 | 1170186.972 |
| 8 | 346439.679 | 1170060.503 | 30 | 347549.052 | 1170326.908 |
| 9 | 346802.179 | 1169688.034 | 31 | 347538.351 | 1170606.869 |
| 10 | 346818.729 | 1169690.413 | 32 | 347425.431 | 1170626.221 |
| 11 | 346852.414 | 1169706.583 | 33 | 347420.028 | 1170623.114 |
| 12 | 346877.031 | 1169685.866 | 34 | 347201.903 | 1170622.121 |
| 13 | 346893.131 | 1169693.845 | 35 | 347193.225 | 1170745.587 |
| 14 | 346922.613 | 1169719.899 | 36 | 347060.603 | 1170780.184 |
| 15 | 346954.341 | 1169739.644 | 37 | 346954.273 | 1170898.329 |
| 16 | 347013.100 | 1169774.221 | 38 | 346895.200 | 1171040.103 |
| 17 | 347044.018 | 1169797.298 | 39 | 346865.664 | 1171140.526 |
| 18 | 347095.151 | 1169809.989 | 40 | 346828.909 | 1171177.282 |
| 19 | 347138.155 | 1169834.381 | 41 | 346826.681 | 1171053.129 |
| 20 | 347171.872 | 1169847.756 | 42 | 346816.553 | 1170488.860 |
| 21 | 347227.041 | 1169855.324 | 43 | 346808.357 | 1170032.253 |
| 22 | 347249.098 | 1169899.282 | 44 | 346803.908 | 1169784.363 |